FARMER NOTES

ព្រឹត្តិប័ត្រព័ត៌មានកសិករ



ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute

# ជំងឺរលួយគល់

## និយមន័យ

ជំងឺរលួយគល់ គឺជាជំងឺម្យ៉ាងដែលបង្កឡើងដោយបាក់តេរីឈ្មោះ អ៊ីវីនីយ៉ា គ្រីសាន់ដឺមី

## រោគសញ្ញានៃជំងឺ

សញ្ញាណជំងឺនេះលេចចេញដំបូង គឺស្លឹកស្រូវប្រែពណ៌លឿង រីឯដើមស្រូវរលួយពណ៌ត្នោតខ្មៅ ។ ដំណាក់កាលដំបូងនៃជំងឺនេះ ចាប់ផ្តើមចេញលើដើមបែកខ្ញីៗ ។ នៅពេលដែលវាចាប់ផ្តើមបំផ្លាញ ស្រទបស្លឹកក៏ចាប់ផ្តើមរលួយ ហើយក៏ប្រែទៅជាពណ៌ត្នោត ។ សញ្ញាណនៃការខូចខាតនោះរាលដាលយ៉ាងលឿនឆ្ពោះទៅរកថ្នាំង ហើយបន្តរហូតទៅដល់ចុងដើមស្រូវទៀត ។ ដើមស្រូវឡើងទន់ហើយរលួយ និងមានក្លិនស្អុយថែមទៀត។ ដំណាក់កាលធ្ងន់ធ្ងរ ដើមបែកជាច្រើនរលួយ ហើយដើមស្រូវទាំងមូលដួលតែម្តង ដែល



អាចចាប់ដកវាចេញបានដោយស្រួលដែរ ។ ជាធម្មតាគេសង្កេតឃើញជំងឺរលួយគល់នេះ បង្កឡើង ចាប់ពី

ពេលស្រូវបែកគុម្ពអតិបរិមារហូតដល់វគ្គបង្កបង្កើតផល ប៉ុន្តែវាអាចបំផ្លាញស្រូវនៅដំណាក់កាលលូតលាស់ ប្រសិនណាបើស្រែលិចទឹក ។

**ការរាលដាលនៃជំងឺ**

ជំងឺនេះរាលដាលខ្លាំងនៅពេលដែលស្រែមិនមានទឹក អាកាសធាតុក្តៅខ្លាំង និងសំណើមបរិយាកាសខ្ពស់ ។ នៅពេលដែលនៅជុំវិញស្រែមានព្រៃដុះស៊ុបទ្រុប និងនៅក្នុងស្រែមានជញ្ជ្រាំង ដែលជាប្រភពចម្លងជំងឺ ធ្វើឱ្យការរាលដាលរបស់វាមានការកើនឡើងលឿន ។

**វិធានការការពារ**

១.ការដាំដំណាំឆ្លាស់ គឺដើម្បីបំបាត់ជម្រកជំងឺ

២.ការភ្ជួរដីត្រូវបំបែកដីឲ្យទៅជាដុំតូចៗ និងលប់កាកសំណល់ដើម្បីឲ្យវាឆាប់រលួយ និងសម្លាប់ស្មៅ

៣.ត្រូវពន្លិកទឹកដីស្រែ និងបង្ហាប់ដី

៤. ត្រូវធ្វើថ្នាលសំណាបឲ្យបានល្អជៀសវាងការរីករាលដាលនៃភ្នាក់ងារចម្លងរបស់ជំងឺ

៥.ពន្យាពេលដាំដុះនៅក្នុងរដូវភ្លៀងធ្លាក់ ព្រោះភ្នាក់ងារចម្លងជំងឺខ្វះនូវសារធាតុចិញ្ចឹម ការអូសបន្លាយនៅក្នុងកំឡុងពេលដំណាក់កាលរលួយ វាធ្វើឲ្យបាក់តេរីមានសភាពខ្សោយ ។

**វិធានការកំចាត់**

១.ត្រូវធ្វើការដកចោលជាបន្ទាន់ នូវគុម្ពស្រូវណាដែលកើតមានជំងឺរលួយគល់នេះ។

២.ប្រើថ្នាំពុលកសិកម្ម តូប៉ង់ ដោយប្រើក្នុងកម្រិត ៖ លាយ ១០-២០ក្រាម/ធុង៨លីត្រ បាញ់៤ធុងលើផ្ទៃដី ១ ០០០ ម៉ែត្រការ៉េ ។ ត្រូវយកចិត្តទុកដាក់ ៖

-បាញ់ថ្នាំនៅពេលដែលស្នាមជំងឺទើបតែលេចឡើង

-កុំបាញ់ថ្នាំមុនពេលប្រមូលផល ១៤ ថ្ងៃ។